សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMICS (RULE)

ខាក្យសព្ទគតិយុត្ត

ក្នុង

និតិព្រហ្មទណ្ឌ

ដកស្រង់ចេញពី: នីតិព្រហ្មទណ្ឌ និង នីតិវ្រូសា

រៀបរៀងដោយ: សាស្ត្រាចារ្យ រុន ណារ៉ុន និង ចាំង ស៊ីណាត

ឆ្នាំ ២០១៧

នាំមកសិក្សាដោយ: អឿង សំអាង

២០២១

ក. ការពន្យល់ពាក្យ

១.	ការការពារស្របច្បាប់	ជាយុត្តិកម្មនៃបទល្មើស ដែលកើតឡើងដោយសារតែអំពើរបស់បុគ្គលណាម្នាក់ ដែលបន្ទាប់ពីបានរងនូវការឈ្លានពានដោយអយុត្តិធម៌ ក៏ធ្វើការតបតភ្លាមៗ ចាំបាច់ដើម្បីការពារខ្លួន ឬ អ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ហើយមានលក្ខណៈសមាមាត្រទៅនឹងអំពើឈ្លានពានខាងលើ។
២.	ការគិតទុកជាមុន	ជាគម្រោងដែលបានបង្កើតឡើង មុនអំពើប្រែតប្រែនទៅលើរូបបុគ្គលនៃជនរងគ្រោះ។
៣.	ការងារសហគមន៍	ជាទោសជំនួស ដែលតម្រូវឱ្យជនជាប់ចោទត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ ម៉ោង ទៅ ២០០ ម៉ោង នូវការងារគ្មានកម្រៃទុកជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬ នីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬ ដល់អង្គការមិនមែនរដ្ឋាភិបាល។
៤.	ការប៉ុនប៉ង	ជាការចាប់ផ្តើមប្រព្រឹត្តបទល្មើស ដែលត្រូវបានអាក់ខានទៅវិញមុនពេលបទល្មើសបានសម្រេចផល ដោយសារតែមានកាលៈទេសៈក្រៅពីឆន្ទៈរបស់ចារី។
៥.	ការបូកទោស	ជាគោលការណ៍មួយ ដែលតម្រូវឱ្យទោសដែលបានប្រកាសឡើងសម្រាប់បទល្មើសនីមួយៗ ត្រូវតែយកទៅបូកបញ្ចូលគ្នា នៅពេលដែលត្រូវអនុវត្តទោស។

Scanned with CamScanner

៦.	ការផ្តល់នីតិសម្បទា	ជាយន្តការច្បាប់មួយប្រភេទ ដែលបានធ្វើការលុបបំបាត់ចោលនូវការផ្តន្ទាទោស និង ផលវិបាកនៃការផ្តន្ទាទោស។ ជាក់ស្តែង តាមក្រមនីតិវិធីព្រហ្មទណ្ឌ ការផ្តល់នីតិសម្បទាមានពីរប្រភេទគឺ៖ ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ និង ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់។
៧.	ការផ្អាកការប្រកាសទោស	ជាការបង្ហង់ការប្រកាសទោសក្នុងរយៈពេលមួយ បន្ទាប់ពីតុលាការបានរកឃើញពិរុទ្ធភាពរួចហើយ នៅក្នុងករណីដែលមានការចោទប្រកាន់ពីបទមជ្ឈិម ហើយជនជាប់ចោទដែលមានវត្តមានក្នុងពេលសវនាការ បានស្នើសុំពេលមួយរយៈ ដើម្បីធ្វើការជួសជុលការខូចខាត។
៨.	ការពន្ធនាគារ	ជាអំពើឃ្លាំឃ្លាំងចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលណាមួយ ដើម្បីប្រព្រឹត្តអំពើហឹង្សាទៅលើរូបបុគ្គលនៃជនរងគ្រោះ។
៩.	ការព្យួរទោស	ជាការលើកចោលដោយមានលក្ខខណ្ឌ នូវការអនុវត្តមូលទោស ដែលត្រូវបានប្រកាសដោយតុលាការ។ បើផ្អែកតាមក្រមព្រហ្មទណ្ឌ ការព្យួរទោសមានពីរប្រភេទគឺ៖ ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។
១០.	ការព្យួរទោសធម្មតា	ជាការព្យួរទោស ដែលមិនតម្រូវឱ្យជនជាប់ទោសមានកាតព្វកិច្ចពិសេសណាមួយទេ ក៏ប៉ុន្តែជនជាប់ទោសមិនត្រូវប្រព្រឹត្តបទល្មើសណាមួយ ក្នុងរយៈពេលសាកល្បងចំនួន ៥ ឆ្នាំ បើពុំដូច្នោះទេ ការព្យួរទោសនេះអាចនឹងត្រូវដកហូតវិញបាន។

Scanned with CamScanner

១១.	**ការព្យួរទោសសាកល្បង**	ជាការព្យួរទោស ដែលមានអានុភាពធ្វើឱ្យជនជាប់ទោសត្រូវស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និង ត្រូវគោរពកាតព្វកិច្ចដោយខ្លែកមួយ ឬ ច្រើននៅក្នុងរយៈពេលសាកល្បងដែលត្រូវបានកំណត់ចាប់ពី ១ឆ្នាំ ដល់ ៣ឆ្នាំ។
១២.	**ការភ័ន្តច្រឡំ**	ជាស្ថានភាពរបស់បុគ្គលម្នាក់ ដែលបានវាយតម្លៃខុសទៅលើអត្ថិភាព ឬគុណភាពនៃអង្គហេតុណាមួយ ឬក៏ទៅលើអត្ថិភាព ឬការបកស្រាយវិធានច្បាប់ណាមួយ។
១៣.	**ការមិនរាងចាល**	ជាមូលហេតុនៃស្ថានទម្ងន់ទោស ដែលបណ្តាលមកពីការប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀត ដោយជនល្មើសដដែល ក្រោយពីបានទទួលរងនូវការផ្តន្ទាទោសជាស្ថាពរម្តងរួចហើយ ស្របតាមលក្ខខណ្ឌដែលត្រូវបានកំណត់យ៉ាងត្រឹមត្រូវដោយច្បាប់។
១៤.	**ការរឹបអូស**	ជាទោសបន្ថែមដែលមានកម្មវត្ថុ ដកហូតយកនូវទ្រព្យសម្បត្តិរបស់ជនជាប់ទោស ក្នុងបទល្មើសមួយចំនួន។
១៥.	**ការលើកលែងទោស**	ជាការអនុគ្រោះទោសដែលប្រទានដោយព្រះមហាក្សត្រ ហើយដែលមានអានុភាពបញ្ឈប់ការអនុវត្តទោសដែលប្រកាសដោយតុលាការ។
១៦.	**ការលើកលែងទោសជាទូទៅ**	ជាវិធានការនីតិកម្ម ដែលមានគោលដៅលុបចោលនូវលក្ខណៈជាបទល្មើសនូវអំពើមួយចំនួន។ ការលើកលែងទោសជាទូទៅស្ថិតក្នុងអំណាចរបស់អង្គការនីតិប្បញ្ញត្តិ។

Scanned with CamScanner

១៧.	ការសមគំនិត	ជាការជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយការផ្តល់ជំនួយ ឬការឧបត្ថម្ភផ្សេងៗដល់ចារីនៃបទល្មើស។
១៨.	ការស្តាយក្រោយសកម្ម	ជាសកម្មភាពរបស់បុគ្គលម្នាក់ ក្នុងការខិតខំប្រឹងប្រែងលុបលាងចេញនូវអានុភាពនៃបទល្មើស ក្រោយពីបានសម្រេចបទល្មើសរួចរាល់ហើយ។
១៩.	ការស្របទោស	ជាការប្រកាសទោសតែមួយ ក្នុងព្រំដែននៃអតិបរមាស្របច្បាប់ខ្ពស់ជាងគេ នៅក្នុងករណីដែលមានបទល្មើសត្រួតគ្នា ហើយដែលត្រូវផ្តន្ទាដោយទោសមានប្រភេទដូចគ្នា។
២០.	ការអនុគ្រោះទោស	ជាការបន្ធូរបន្ថយទោស ឬ ការលើកលែងទោសដែលបានប្រទានដោយព្រះមហាក្សត្រ។
២១.	កូនក្តី	ជាបុគ្គលដែលមានវិវាទនឹងគ្នា ហើយសម្រេចប្តឹងផ្តល់គ្នាទៅតុលាការ។
២២.	កំហុស	ជាធាតុផ្សំអត្តនោម័តនៃបទល្មើសព្រហ្មទណ្ឌ។
២៣.	កំហុសចេតនា	ជាធាតុផ្សំអត្តនោម័តនៃបទល្មើសដោយចេតនា ដែលសំដៅទៅលើចេតនារបស់បុគ្គលម្នាក់ ដែលមានសេរីភាព និង មានមនសិការគ្រប់គ្រាន់ ក្នុងការស្វែងរកលទ្ធផលដែលច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។
២៤.	កំហុសអចេតនា	ជាកំហុសដែលកើតឡើងពីការមិនអាចគ្រប់គ្រងឆន្ទៈរបស់ខ្លួនឯងបាន មានន័យថា ចារីមានបំណងធ្វើសកម្មភាព

Scanned with CamScanner

ល្មើសរបស់ខ្លួន ក៏ប៉ុន្តែ ចារីមិនមានឆន្ទៈ ឬ ពុំបានដឹងជាមុនពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនឡើយ។

២៥.	**កោសលវិច័យ**	ជាប្រតិបត្តិការរបស់អ្នកជំនាញ ក្នុងការពិនិត្យពិច័យទៅលើបញ្ហាអង្គហេតុណាមួយដែលចៅក្រមត្រូវការឱ្យធ្វើការបំភ្លឺ។
២៦.	**ក្រមព្រហ្មទណ្ឌ**	ជាច្បាប់ដែលបានចងក្រងនូវបទប្បញ្ញត្តិព្រហ្មទណ្ឌ។
២៧.	**ក្រុមប្រឹក្សាជំនុំជម្រះ**	ជាក្រុមចៅក្រមដែលជំនុំជម្រះជាសមូហភាព លើរឿងក្តីណាមួយនៅតាមសាលាជម្រះក្តី។
២៨.	**គោលការណ៍**	ជាវិធានគតិយុត្តផ្សេងៗដែលត្រូវបានបង្កើតឡើង ដោយប្រើប្រាស់ពាក្យពេចន៍យ៉ាងទូលំទូលាយ និង ដែលជាមូលដ្ឋានចាំបាច់នៃការអនុវត្តផ្សេងៗ ហើយដែលត្រូវតែយកទៅអនុវត្ត និងត្រូវតែគោរពតាមយ៉ាងខ្ជាប់ខ្ជួន។
២៩.	**ឃាតកម្ម**	ជាអំពើសម្លាប់អ្នកដទៃដោយចេតនា។
៣០.	**ចរិតលក្ខណៈនៃទោស**	ជាសភាពលក្ខណៈនៃទោស ដែលជាទូទៅមានបីយ៉ាងគឺ ចរិតលក្ខណៈនីត្យានុកូល សមភាព និង ឯកត្តជន។
៣១.	**ចារី**	ជាបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលត្រូវបានចោទប្រកាន់។
៣២.	**ចារីបញ្ញា**	ជាចារីក្នុងអំពើបញ្ហា ឬឱ្យយោបល់ដល់តតិយជនក្នុងការប្រព្រឹត្តអំពើល្មើស ហើយដែលច្បាប់បានហាមឃាត់អំពើបញ្ហា ឬ ឱ្យយោបល់នោះយ៉ាងច្បាស់លាស់។

Scanned with CamScanner

៣៣.	ចេតនាទុច្ចរិត	ជាសម្បជញ្ញៈយល់ដឹងច្បាស់លាស់ និងមានឆន្ទៈដោយសេរីក្នុងការបំពានបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ។ ចេតនាទុច្ចរិត គឺជាធាតុផ្សំអត្តនោម័តនៃបទល្មើសព្រហ្មទណ្ឌ។
៣៤.	ចេតនាទុច្ចរិតពិសេស	ជាធាតុផ្សំផ្នែកបញ្ញាស្មារតី ដែលត្រូវបានកំណត់យ៉ាងជាក់ច្បាស់ ហើយសំដៅទៅលើចេតនាដែលរំពឹងទុកជាមុនថា នឹងទទួលបាននូវលទ្ធផលជាក់លាក់ណាមួយ ដែលច្បាប់ព្រហ្មទណ្ឌបានហាមឃាត់ ពោលគឺចារីចង់បាននូវលទ្ធផលពិសេសណាមួយ សម្រាប់បទល្មើសដែលខ្លួនបានប្រព្រឹត្ត។
៣៥.	ឆន្ទានុសិទ្ធិ	ជាសិទ្ធិដែលសម្រេចបានតាមទំនើងចិត្ត។
៣៦.	ជនជាប់ចោទ	ជាបុគ្គលដែលត្រូវបានបញ្ជូនទៅតុលាការ ដើម្បីជំនុំជម្រះតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនទៅតុលាការជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា ឬ តាមកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម ដែលបានធ្វើឡើងដោយព្រះរាជអាជ្ញា។
៣៧.	ជនជាប់ទោស	ជាបុគ្គលដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសជាស្ថាពរ។
៣៨.	ជនត្រូវចោទ	ជាបុគ្គលដែលត្រូវបានចោទប្រកាន់ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

Scanned with CamScanner

៥៩.	ជនរងគ្រោះ	ជាជនដែលទទួលរងនូវការខូចខាត (ការខូចខាតផ្លូវកាយ ផ្លូវចិត្ត និង ទ្រព្យសម្បត្តិ) ដោយសារតែការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ។
៦០.	ជនល្មើស	ជាជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។
៦១.	ញាតិលោហិត	ជាញាតិដែលមានឈាមជាប់ជាមួយគ្នា រួមមានដូចជា ឪពុក ម្តាយ និងកូន ជាដើម។
៦២.	ដើមបណ្តឹងរដ្ឋប្បវេណី	ជាភាគីម្ខាងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលបានទទួលរងគ្រោះដោយសារតែបទល្មើសព្រហ្មទណ្ឌ ហើយបានប្តឹងទាមទារសំណងនៃការខូចខាតពីជនល្មើស តាមរយៈពាក្យប្តឹងសាមញ្ញ ឬ តាមពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។
៦៣.	តតិយជន	ជាបុគ្គលទីបី ក្រៅពីភាគី។
៦៤.	តុលាការ	ជាស្ថាប័នដែលមានអំណាចក្នុងការជំនុំជម្រះសេចក្តី។
៦៥.	តុលាការកំពូល	ជាសាលាជម្រះក្តីជាន់ខ្ពស់ ដែលមានសមត្ថកិច្ចធ្វើការជំនុំជម្រះលើបណ្តឹងជំទាស់ ឬបណ្តឹងសាទុក្ខពីដីកាសម្រេច ឬសាលដីការបស់សាលាឧទ្ធរណ៍។
៦៦.	តុលាការមានសមត្ថកិច្ច	ជាតុលាការដែលច្បាប់ បានកំណត់ឱ្យមានអំណាចក្នុងការជំនុំជម្រះលើរឿងក្តីណាមួយ។
៦៧.	ទោស	ជាទណ្ឌកម្មដែលត្រូវផ្តន្ទាទៅលើជនល្មើស ដោយសារតែការប្រព្រឹត្តបទល្មើសណាមួយ ។ ទោសមានបីប្រភេទគឺ មូលទោស ទោសបន្ថែម និង ទោសជំនួស។

Scanned with CamScanner

៤៨.	ទោសជំនួស	ជាទោសដែលតុលាការអាចប្រកាស ជំនួសមូលទោសបានតាមការកំណត់របស់ច្បាប់។ បើយោងតាមក្រមព្រហ្មទណ្ឌ ទោសជំនួសមានពីរប្រភេទគឺ ៖ ការងារសហគមន៍ និង ការស្តីបន្ទោស។
៤៩.	ទោសដាក់ពន្ធនាគារ	ជាទោសដែលបំបាត់ស្ទើរតែទាំងស្រុង នូវសេរីភាពជាមូលដ្ឋានរបស់ចារី ដោយមានកំណត់កាល ហើយដែលត្រូវតែអនុវត្តនៅក្នុងពន្ធនាគាររបស់រដ្ឋ។
៥០	ទោសបន្ថែម	ជាទោសដែលតុលាការមិនអាចសម្រេចផ្តន្ទា ឱ្យជាចំពែងឯងបានទេ គឺថាតុលាការនឹងសម្រេចផ្តន្ទាទោសបន្ថែមបាន លុះត្រាតែតុលាការបានសម្រេចពីមូលទោសណាមួយជាមុនសិនទើបបាន។
៥១.	ទោសប្រហារជីវិត	ជាទោសដែលនាំឱ្យមានការសម្លាប់ជីវិតរបស់ទណ្ឌិត។
៥២.	ទោសពិន័យ	ជាទោសដែលតម្រូវឱ្យ ទណ្ឌិតបង់ចំនួនប្រាក់កំណត់ដោយច្បាប់ ហើយប្រាក់នេះត្រូវបង់ចូលជាថវិការដ្ឋ។
៥៣.	ទោសរួម	ជាទោសដែលតុលាការបានប្រកាសជារួម សម្រាប់អនុវត្តលើបទល្មើសច្រើនតគ្នា។
៥៤.	ធាតុផ្សំនៃបទល្មើស	ជាលក្ខខណ្ឌដែលច្បាប់បានកំណត់ថា អាចរួមផ្សំបង្កើតជាបទល្មើសព្រហ្មទណ្ឌ។
៥៥.	ធាតុផ្សំសច្ចានុម័ត	ជាធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដែលចង់សំដៅជាពិសេសទៅលើសកម្មភាព ឬ អសកម្មភាពរបស់ចារី។
៥៦.	ធាតុផ្សំវត្ថុនាម័ត	ជាធាតុផ្សំនៃបទល្មើស ដែលសំដៅទៅលើកំហុសរបស់

Scanned with CamScanner

ចារីក្នុងការប្រព្រឹត្តបទល្មើស។ ជាធម្មតា កំហុសនេះមានពីរប្រភេទគឺ ៖ កំហុសចេតនា និង កំហុសអចេតនា។

៥៧.	**នីត្យានុកូលភាព**	ជាភាពពេញលក្ខណៈច្បាប់។
៥៨.	**នីតិជន**	ជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។
៥៩.	**នីតិបុគ្គល**	ជាក្រុមដែលមានសមាជិក ឬ ទ្រព្យសម្បត្តិវិភាគទានដែលត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ។ នីតិបុគ្គលមានពីរប្រភេទគឺ នីតិបុគ្គលសាជីវកម្ម និង នីតិបុគ្គលមូលនិធិ។
៦០.	**នីតិព្រហ្មទណ្ឌ**	ជាវិធានច្បាប់ដែលចែងយ៉ាងច្បាស់លាស់ទុកជាមុននូវបទល្មើស ទោស និងការទទួលខុសត្រូវព្រហ្មទណ្ឌ។
៦១.	**នីតិភាព**	-ជាអាយុដែលកំណត់ដោយច្បាប់ ហើយដែលនៅពេលបានដល់អាយុនោះ បុគ្គលម្នាក់ៗត្រូវបានសន្មតថាមានសមត្ថភាពចំពោះការធ្វើសកម្មភាពផ្សេងៗ។ -យោងតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី អនីតិជនដែលទទួលបាន **អត្តាធីនភាព** ត្រូវចាត់ទុកថា បានដល់នីតិភាព (មាត្រា ៦២ នៃក្រមរដ្ឋប្បវេណី)។
៦២.	**នីតិវិធី**	ជាបណ្តាវិធានទាំងឡាយដែលដឹកនាំដំណើរការរឿងក្តី។
៦៣.	**បញ្ជីផ្តាំលទោស**	ជាសម្រង់ផ្តាំកជាតិ និងជាស្វ័យប្រវត្តិនូវការផ្តន្ទាទោសព្រហ្មទណ្ឌលើបុគ្គលណាមួយ ។ បញ្ជីផ្តាំលទោសត្រូវគ្រប់គ្រងដោយក្រសួងយុត្តិធម៌។

Scanned with CamScanner

៦៤.	បណ្តឹងផ្តួលរំលំ	ជាបណ្តឹងដែលមានគោលបំណងធ្វើឱ្យបាន នូវការជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើស ដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធូនល្មមនឹងព្យសនកម្ម ដែលខ្លួនបានទទួលរង។
៦៥.	បណ្តឹងអាជ្ញា	ជាបណ្តឹងដែលមានគោលបំណងដ៏សំខាន់ ក្នុងការពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។ អង្គការអយ្យការគឺជាម្ចាស់បណ្តឹងអាជ្ញា។
៦៦.	បទប្បញ្ញត្តិ	ជាវិធានដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តណាមួយ ដូចជាច្បាប់ ឬបទបញ្ជា ជាដើម។
៦៧	បទលហុ	ជាបទល្មើសដែលច្បាប់បានកំណត់អតិបរមានៃទោសដាក់ពន្ធនាគាររយៈពេលក្រោម ឬ ស្មើនឹង ៦ថ្ងៃ ឬបទល្មើសដែលច្បាប់កំណត់ ត្រឹមតែការផ្តន្ទាទោសពិន័យជាប្រាក់ប៉ុណ្ណោះ។
៦៨.	បទល្មើស	ជាអំពើដែលត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយក៏ជាកំហុសរបស់ចារីផ្ទាល់។
៦៩.	បទល្មើសដោយចេតនា	ជាបទល្មើសដែលចារីមានចេតនាប្រព្រឹត្ត។
៧០.	បទល្មើសដោយអចេតនា	ជាបទល្មើសដែលកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពការតម្រឹកិច្ចដោយខ្លែកណាមួយ។

Scanned with CamScanner

៧១.	**បទល្មើសត្រួតគ្នា**	ជាបទល្មើសច្រើន ដែលត្រូវបានប្រព្រឹត្តក្នុងពេលតែមួយ ឬពេលខុសគ្នាដោយចារឹតដែល នៅមុនពេលដែលមានការផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសណាមួយ។
៧២.	**បទល្មើសធម្មតា**	ជាបទល្មើសដែលសម្រេចឡើងដោយអំពើជាសត្បាទុម័តតែមួយប៉ុណ្ណោះ។
៧៣.	**បទល្មើសនយោបាយ**	ជាបទល្មើសដែលបានបង្កនូវការគំរាមកំហែងដល់ផលប្រយោជន៍ ឬ បុព្វសិទ្ធិដែលមានលក្ខណៈនយោបាយ ដូចជាការធ្វើរដ្ឋប្រហារ ជាដើម។
៧៤.	**បទល្មើសបន្តរៀងហូរហែ**	ជាបទល្មើសដែលអំពើជាសម្ភារៈ ត្រូវបានប្រព្រឹត្តឡើងបន្តគ្នាជាហូរហែនិងដោយស៊ីសង្វាក់គ្នានៅក្នុងពេលវេលា។
៧៥.	**បទល្មើសភ្លាមៗ**	ជាបទល្មើសដែលអាចសម្រេចបាន ក្នុងរយៈពេលតែមួយភ្លែតប៉ុណ្ណោះ។
៧៦.	**បទល្មើសយោធា**	ជាបទល្មើសដែលបានប្រព្រឹត្តដោយយោធិន នៅក្នុងជួរកងទ័ព ហើយដែលមានការពាក់ព័ន្ធនឹងវិន័យកងទ័ព ឬក៏ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ។
៧៧.	**បទល្មើសសកម្ម**	ជាបទល្មើស ដែលមានធាតុផ្សំសត្បាទុម័តជាសកម្មភាព ឬជាអំពើវិជ្ជមានណាមួយ។
៧៨.	**បទល្មើសស្មុគស្មាញ**	ជាបទល្មើសដែលបានសម្រេចឡើង ដោយរួមមានអំពើជាសត្បាទុម័តច្រើនគួបផ្សំគ្នា។
៧៩.	**បទល្មើសសាមញ្ញ**	ជាបទល្មើសដែលស្ថិតនៅក្រោម វិធានច្បាប់ព្រហ្មទណ្ឌទូទៅ ហើយមានភាពខុសប្លែកពីបទល្មើសពិសេស ដូចជាបទល្មើសយោធា ជាដើម។

Scanned with CamScanner

៨០.	បទល្មើសអកម្ម	ជាបទល្មើសដែលមានឆាតុជ្ឈិសត្បានុម័តជាអំពើអវិជ្ជមានណាមួយ ពោលគឺចារីមិនបានធ្វើអំពើណាមួយដែលច្បាប់បានតម្រូវឱ្យធ្វើ។
៨១.	បទល្មើសអូសបន្លាយ	ជាបទល្មើសដែលរួមផ្សំដោយអំពើដែលបានបង្កគ្រោះថ្នាក់ដល់សង្គម ហើយដែលបានស្ថេរឡើងជាប់ជាហូរហែគ្មានអាក់ខាន ក្នុងរយៈពេលណាមួយ។
៨២.	បទឧក្រិដ្ឋ	ជាបទល្មើសដែលច្បាប់បានកំណត់អតិបរមានៃទោសដាក់ពន្ធនាគារ ជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ឆ្នាំ និងក្រោម ឬស្មើ ៣០ ឆ្នាំ។
៨៣.	ប្រតិសកម្ម	ជាគុណសម្បត្តិនៃអ្វីៗដែលបានរាថយទៅរកអតីតកាល។
៨៤.	ប្រទុស្តកេរខ្មាស	ជាអំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ ដោយមិនមានការយល់ព្រមពីបុគ្គលនេះ ឬជាអំពើបង្ខំឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន (ជនល្មើស) ឬ ទៅលើតតិយបុគ្គល ក្នុងគោលបំណងធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។
៨៥.	ផលនៃបទល្មើស	ជាទ្រព្យសម្បត្តិដែលបានមកពីការប្រព្រឹត្តបទល្មើសផ្សេងៗ។
៨៦.	ព្យសនកម្ម	ជាការខូចខាតផ្សេងៗ ដែលរួមមាន ការខូចខាតផ្នែកសម្ភារៈ ការខូចខាតផ្នែកផ្លូវចិត្ត ឬផ្លូវកាយ ដែលបានទទួលរងដោយជនរងគ្រោះ។

Scanned with CamScanner

៨៧.	ពាក្យបណ្តឹង ឬ ពាក្យប្តឹង	ជាលិខិតដែលបង្ហាញឱ្យឃើញ ពីការប្តឹងផ្តល់ណាមួយ ដើម្បីទទួលបាននូវការគោរពសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់បុគ្គល។
៨៨.	ពិរុទ្ធភាព	ជាភាពមានកំហុស។
៨៩.	ភស្តុតាង	ជាការចង្អុលបង្ហាញឱ្យឃើញនូវអត្ថិភាពនៃអំពើ ឬក៏សកម្មភាពគតិយុត្តណាមួយ។
៩០.	មូលទោស	ជាទោសដែលចៅក្រមយកទៅសម្រេច ឱ្យដាច់តែឯងក៏បាន ដោយអាចបញ្ចូលនូវទោសបន្ថែមក៏បាន ឬ មិនបញ្ចូលក៏បានដែរ។
៩១.	មោឃភាព	-ជាភាពពុំមានអានុភាពតាមផ្លូវច្បាប់ នៃសកម្មភាពគតិយុត្តដែលផ្ទុយនឹងបញ្ញត្តិស្តីអំពីនីតិវិធីនៃបណ្តឹង។ -ជាទណ្ឌកម្មដែលប្រកាសដោយចៅក្រម ដើម្បីលុបបំបាត់ចោលជាប្រតិសកម្មនូវសកម្មភាពណាមួយ ដែលមិនបានបំពេញលក្ខខណ្ឌដែលច្បាប់កំណត់ ឬ សកម្មភាពណាមួយដែលផ្ទុយពីនីតិវិធីនៃច្បាប់។
៩២.	យុត្តិកម្មនៃបទល្មើស	ជាអំពើដែលច្បាប់ព្រហ្មទណ្ឌបានចាត់ទុកថាជាបទល្មើស ក៏ប៉ុន្តែច្បាប់មិនតម្រូវឱ្យផ្តន្ទាទោសទេ ដោយសារតែការប្រព្រឹត្តបទល្មើសនេះធ្វើឡើងដោយត្រឹមត្រូវ។ យុត្តិកម្មនៃបទល្មើសរួមមាន ៖ ការការពារស្របច្បាប់ ស្ថានភាពចាំបាច់ ការអនុញ្ញាតដោយច្បាប់ ឬ ដោយអាជ្ញាធរស្របច្បាប់។

Scanned with CamScanner

៥៣.	របបពាក់ព័ន្ធសេរីភាព	ជារបៀបរបបនៃការរៀបចំទោស ដែលអាចអនុញ្ញាតឱ្យទណ្ឌិតអាចនៅក្រៅពន្ធនាគារបាន ក្នុងរយៈពេលដែលបានកំណត់ដោយតុលាការ។
៥៤.	វិធានការសន្តិសុខ	ជាវិធានការដែលមានលក្ខណៈប្រហាក់ប្រហែលនឹងទោស ប៉ុន្តែមិនត្រូវបានចាត់ទុកថាជាទោសឡើយ ដូចជាវិធានការព្យាបាលអ្នកញៀនគ្រឿងញៀន ជាដើម។
៥៥.	វិបល្លាសស្មារតី	ជាវិបត្តិដែលធ្វើឱ្យមានភាពរីករាលដល់សកម្មភាពនៃសរសៃប្រសាទរបស់មនុស្ស ហើយដែលអាចបណ្តាលមកពីជរាភាព គ្រោះថ្នាក់ ឬ ជម្ងឺ ជាដើម។
៥៦.	សភាព្រហ្មទណ្ឌ	ជាសភាមួយនៃសាលាឧទ្ធរណ៍ ឬ នៃតុលាការកំពូល ដែលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខពីសាលក្រម ឬ សាលដីកាក្នុងរឿងក្តីព្រហ្មទណ្ឌ។
៥៧.	សភាស៊ើបសួរ	ជាសភាមួយនៃសាលាឧទ្ធរណ៍ ដែលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ លើបណ្តឹងមោឃភាពនៃកិច្ចនីតិវិធី និង លើបណ្តឹងផ្ទាល់ពីចំណាត់ការរបស់ចៅក្រមស៊ើបសួរ។
៥៨.	សហចារី	ជាបុគ្គលច្រើននាក់ដែលបានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នា ដោយផ្ទាល់។
៥៩.	សហព័ទ្ធ	ជាប្តី ឬ ប្រពន្ធ។

Scanned with CamScanner

១០០.	**សាក្សី**	ជាជនដែលបានដឹង បានឮ ឬ បានឃើញហេតុការណ៍ផ្សេងៗដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ។
១០១.	**សាលក្រម**	ជាសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ទាប។
១០២.	**សាលាដំបូង**	ជាសាលាជម្រះក្តីជាន់ទាប ដែលសម្រេចសេចក្តីលើវិវាទព្រហ្មទណ្ឌ ក្រៅពីបទល្មើសយោធា វិវាទរដ្ឋប្បវេណី វិវាទការងារ វិវាទពាណិជ្ជកម្ម និងវិវាទរដ្ឋបាល។
១០៣.	**សាលាឧទ្ធរណ៍**	ជាសាលាជម្រះក្តីជាន់ខ្ពស់ ដែលមានសមត្ថកិច្ចធ្វើការជំនុំជម្រះលើបណ្តឹងជំទាស់ ឬ បណ្តឹងឧទ្ធរណ៍ពីដីកាសម្រេច ឬសាលក្រមរបស់សាលាជម្រះក្តីជាន់ទាប។
១០៤.	**សុពលភាព**	ជាភាវៈមានអានុភាពអនុវត្តតាមផ្លូវច្បាប់។
១០៥.	**សំណងជម្ងឺចិត្ត**	ជាចំនួនប្រាក់ដែលត្រូវបង់ឱ្យជនរងគ្រោះ ដើម្បីជួសជុលការខូចខាតដែលគាត់បានទទួលរង ដោយសារតែអំពើរបស់អ្នកដទៃ។
១០៦.	**ស្ថានទម្ងន់ទោស**	ជាស្ថានភាព ឬ គុណភាពនៃអ្វីមួយដែលកំណត់ដោយច្បាប់ ហើយដែលនាំឱ្យមានការផ្តន្ទាទោសធ្ងន់ធ្ងរជាងកម្រិតទោសធម្មតា។
១០៧.	**ស្ថានភាពការពារ**	ជាស្ថានភាពរបស់បុគ្គលម្នាក់ ដែលស្ថិតក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬ ដែលនឹងកើតមាន ដោយប្រើប្រាស់មធ្យោបាយការពារ សមាមាត្រទៅនឹងទម្ងន់នៃគ្រោះថ្នាក់។

Scanned with CamScanner

១០៨.	ស្ថានសម្រាលទោស	ជាកាល:ទេស:នៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ដែលនាំឱ្យតុលាការសម្រេចបន្ថយទោសដល់ជនជាប់ចោទ រហូតដល់ក្រោមអប្បបរមានៃទោសកំណត់ដោយច្បាប់សម្រាប់បទល្មើសណាមួយ។
១០៩.	ហិង្សាដោយចេតនា	ជាអំពើដោយចេតនា ដែលបានធ្វើឱ្យអ្នកដទៃទទួលរងនូវព្យសនកម្ម ដូចជាការវាយតប់ ទាត់ធាក់ ជាដើម។
១១០.	អង្គការនីតិប្រតិបត្តិ	ជាអង្គការដែលមានអំណាចនីតិប្រតិបត្តិ ពោលគឺអំណាចក្នុងការបំពេញកិច្ចការផ្សេងៗ ដែលចាំបាច់ដើម្បីអនុវត្តច្បាប់ លើកលែងតែការដោះស្រាយរឿងក្តីដែលស្ថិតនៅក្រោមអំណាចតុលាការ។
១១១.	អញ្ជត្រកម្ម	ជាការលើកលែង។
១១២.	អនីតិជន	ជាជនដែលមានអាយុក្រោម ១៨ឆ្នាំ។
១១៣.	អនីតិសង្វាសជន	ជាជនដែលបានរួមរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធ ក៏ប៉ុន្តែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ឡើយ។
១១៤.	អភ័យឯកសិទ្ធិ	ជាមូលហេតុនៃការមិនដាក់ទោស ឬ និទ្ទណ្ឌភាពដោយសារតែស្ថានភាពពិសេស របស់ចារីនៃបទល្មើសនៅពេលដែលបានប្រព្រឹត្តបទល្មើសនោះ ដែលជាហេតុនាំឱ្យការចោទប្រកាន់ពីបទល្មើសមិនអាចធ្វើទៅបាន។
១១៥.	អាជ្ញាយុកាល	ជារយៈពេលមួយកំណត់ដោយច្បាប់ ហើយដែលនៅពេលផុតរយៈពេលនេះ បុគ្គលម្នាក់អាចបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬ អាចទាមទារសិទ្ធិណាមួយជាប្រយោជន៍

Scanned with CamScanner

		ដល់ខ្លួន។ នៅក្នុងរឿងព្រហ្មទណ្ឌ អាជ្ញាយុកាលមានពីរប្រភេទគឺ ៖ អាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស។
១១៦.	**អាវុធ**	ជាវត្ថុទាំងអស់ ឬជាឧបករណ៍ដែលធ្វើឡើងដើម្បីសម្លាប់ ឬ ធ្វើឱ្យមានរបួសដល់អ្នកដទៃ។
១១៧.	**អំពើល្មើសផ្នែករដ្ឋប្បវេណី**	ជាអំពើដែលបង្កព្យសនកម្មដល់អ្នកដទៃ ដោយសារតែកំហុសចេតនា ឬ កំហុសអចេតនារបស់ចារី។
១១៨.	**អំពើល្មើសផ្នែកវិន័យ**	ជាអំពើដែលបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជាសមូហភាពនៃក្រុមសង្គមណាមួយ ហើយអំពើនោះមិនត្រូវបានកំណត់ឱ្យច្បាស់លាស់ជាទូទៅទេ។
១១៩.	**អ្នកសមគំនិត**	ជាបុគ្គលដែលបានជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយការផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។
១២០.	**ឯកត្តកម្ម**	ជាការកំណត់នូវបុគ្គលិកលក្ខណៈសម្រាប់បុគ្គលម្នាក់ៗ ឬ វត្ថុណាមួយ។

Scanned with CamScanner